គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការគណបក្ស
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត្យ និងវឌ្ឍនភាពសង្គម

# ផែនការយុទ្ធសាស្ត្រនៃការអភិវឌ្ឍយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៣

ដើម្បីគាំទ្រកម្មវិធីនយោបាយគណបក្សប្រជាជនកម្ពុជា និងការអនុវត្តផែនការសកម្មភាពរបស់ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជា ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព

DRAFT

លេខាធិការដ្ឋាន

ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ខែធ្នូ ឆ្នាំ២០១៨

# បុព្វកថា

ក្នុងរយៈពេលបួនទសវត្សរ៍បន្ទាប់ពីបានទទួលជម្នះលើរបបប្រល័យពូជសាសន៍ពុល ពត ឬ របបរដ្ឋកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ រដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានដាក់ចេញគោល-នយោបាយត្រឹមត្រូវ និងអនុវត្តតាមយុទ្ធសាស្ត្រឈ្នះ ឈ្នះ ដោយសម្រេចនូវសមិទ្ធផលសំខាន់ជាច្រើនជាប្រវត្តិសាស្ត្រក្នុងបុព្វហេតុចំនួន ២ គឺ ទី១. សន្តិភាព និងទី២. ការអភិវឌ្ឍ។ ក្នុងន័យនេះ គណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សរបស់ប្រជាជន ហ៊ានធ្វើពលិកម្មដោយឥតរួញរា ដើម្បីប្រទេសកម្ពុជាមួយ ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹត និងវឌ្ឍនភាពសង្គម។ ទន្ទឹមនេះ គណបក្សប្រជាជនកម្ពុជា បាននិងកំពុងខិតខំនិងធានាការពារ ឱ្យបានជាដាច់ខាតទោះបីជាក្នុងតម្លៃណាក៏ដោយ ហើយជាសត្យានុម័ត ដោយសំអាងលើមេរៀនប្រវត្តិសាស្ត្រនិងមាគ៌ានយោបាយរបស់គណបក្សប្រជាជនកម្ពុជា ច្បាស់ណាស់ថា មានតែគណបក្សប្រជាជនកម្ពុជាតែមួយគត់ ដែលធ្លាប់បានកំពុងធ្វើ និងបន្តធានាទៅមុខទៀតបាននូវបុព្វហេតុទាំង ២ នេះ ជូនប្រជាជនកម្ពុជាយើង។

តាមរយៈការសម្រេចសមិទ្ធផលជាប្រវត្តិសាស្ត្រនេះ ឆ្លុះបញ្ចាំងថា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ផ្ទាល់តែម្តងបានផ្តល់នូវគម្រូវីរភាពនៃការកសាងនិងការសម្រេចបុព្វហេតុជូនជាតិមាតុភូមិ ហើយដែលជាគម្រូទី១ ដ៏ខ្ពស់ត្រដែតបំផុត សម្រាប់យុវជនយើងយកមកពិចារណា កំណត់ដៅឱ្យបានច្បាស់លាស់នូវបុព្វហេតុរបស់ខ្លួន និងរៀបចំផែនការក្នុងការ សម្រេចបានស្នាដៃជាបុព្វហេតុនៃការរួមចំណែកបម្រើឧត្តមប្រយោជន៍ជូនប្រជាជាតិកម្ពុជា តាមអគ្គមគ្គុទ្ទេសក៍របស់យុវជន ជំនាន់មុន។

ក្នុងទស្សនវិស័យដ៏ត្រចះត្រចង់នេះ គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺគាំទ្រកម្មវិធីនយោបាយរបស់គណបក្ស និងបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា ដែលមានសម្តេចតេជោជាបេក្ខភាពនាយករដ្ឋមន្ត្រី។ បន្ថែមពីនេះ លេខាធិការដ្ឋានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តួចផ្តើមរៀបចំ ផែនការយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍យុវជនប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០១៨-២០២៣ ដើម្បីរួចចំណែកគាំទ្រកម្មវិធីនយោបាយគណបក្ស និងលើកស្ទួយតួនាទីរបស់យុវជនចូលរួមគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍យុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០១៨-២០២៣ ដ៏មុតស្រួចនេះ, ខ្ញុំរំពឹងថា យុវជននៃគណបក្សប្រជាជនប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងលើកកម្ពស់នូវពុទ្ធិ និងគុណវុឌ្ឍិ ដូចតទៅ៖

- ទី១. យុវជនយល់ស៊ីជម្រៅអំពីកម្មវិធីនយោបាយ, សារតារ, បុព្វហេតុ និង ទស្សនវិស័យនយោបាយរបស់គណបក្សប្រជាជនកម្ពុជា ព្រមទាំងបង្កើនភាពជាអ្នកដឹកនាំ និងមានគំនិតផ្តួចផ្តើម។
- ទី២. យុវជនមានស្មារតីដ៏រឹងមាំបំផុតនៃការជឿជាក់និងការគាំទ្រដ៏ពិតប្រាកដឥតងាករេ មកលើគណបក្ស និងបង្កើនសក្តានុពលភាពយុវជនសកម្មជនរបស់គណបក្ស ក្នុងបុព្វហេតុបង្កើនជំនឿរបស់ពលរដ្ឋមកលើការដឹកនាំរបស់គណបក្សជានិរន្តរ៍។
- ទី៣. យុវជនមានឱកាសទទួលបានការចែករំលែកបទពិសោធន៍ស្តីពីជីវភាពការងារ និងជីវិតផ្ទាល់របស់ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្ទាល់ និងថ្នាក់ដឹកនាំនៃស្ថាប័នរាជរដ្ឋាភិបាល។

DRAFT

បន្ថែមពីនេះ ក្រុមការងារយុវជនគណបក្សប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននិងកំពុងគិតគូរអំពីលទ្ធភាពនៃការរៀបចំវគ្គបណ្តុះបណ្តាលយុវជនឆ្នើមរបស់យើង ឱ្យក្លាយជាវាគ្មិនបង្គោល ដែលនឹងបំពេញមុខងារគន្លឹះក្នុងការផ្សព្វ-ផ្សាយបន្តអំពីគោលនយោបាយ មាគ៌ានយោបាយ និងទស្សនវិស័យនយោបាយរបស់គណបក្សជូនដល់យុវជនគណបក្សប្រជាជនកម្ពុជា ព្រមទាំងឈានឆ្ពោះទៅផ្សព្វផ្សាយជូនយុវជនមិនមែនសមាជិកគណបក្សរបស់យើង ក្នុងគោលដៅពង្រឹងមូលដ្ឋានគាំទ្រដ៏រឹងមាំ និងលូតលាស់រស់រវើក របស់ប្រជាពលរដ្ឋ មកលើការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា។

ជារួម ខ្ញុំរំពឹងថាឯកសារផែនការយុទ្ធសាស្ត្រនៃការអភិវឌ្ឍយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៣ នេះ នឹងត្រូវប្រើប្រាស់ជាឧបករណ៍ទ្រទ្រង់ទាំងកម្មវិធីនយោបាយគណបក្សប្រជាជនកម្ពុជា ក៏ដូចជាគាំទ្រនៃការអនុវត្តផែនការសកម្មភាពរបស់គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដើម្បីជាឧត្តមប្រយោជន៍ដល់សង្គមជាតិ និងប្រជាជន ជាពិសេសដើម្បីបម្រើបុព្វហេតុនៃការកែទម្រង់ គឺដើម្បីយុវជន រីឯបុព្វហេតុយុវជន គឺដើម្បីការកែទម្រង់ សំដៅឆ្ពោះទៅកាន់គ្រើយតែមួយ គឺការអភិវឌ្ឍនិងវិបុលភាពនៃប្រទេសជាតិរបស់យើង។

ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩

**ប្រធានគណៈកម្មាធិការបក្សប្រជាជនកម្ពុជា**

**ប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

DRAFT

## អារម្ភកថា

លេខាធិការដ្ឋានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានបង្កើតក្នុងបេសកកម្មផ្តល់កាលានុវត្តភាពជូនយុវជន សម្រេចសក្តានុពលរបស់ខ្លួន ជាប្រយោជន៍ដល់ការអនុវត្តគោលនយោបាយរបស់គណបក្សនិងរាជរដ្ឋាភិបាល ក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីគាំទ្រ និងសម្រេចបុព្វហេតុចំនួនពីរ គឺ ទី១. សន្តិភាព និង ទី២.ការអភិវឌ្ឍ។

ដើម្បីចូលរួមបុព្វហេតុជាប្រវត្តិសាស្ត្ររបស់គណបក្សប្រជាជនកម្ពុជា និងគាំទ្រកម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណបក្សប្រជាជនកម្ពុជា,** ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តួចផ្តើម, ដាក់ចេញសកម្មភាពជាច្រើនក្នុងឆ្នាំ២០១៨ និងសម្រេចបាននូវសមិទ្ធផលសំខាន់ៗ ជាច្រើន ដែលក្នុងនោះ រួមមាន÷

**ទី១. រចនាសម្ព័ន្ធចាត់តាំង និងយន្តការការងារ**

- បានរៀបចំក្របខ័ណ្ឌថ្មី, កំណត់ច្បាស់លាស់នូវមុខងារ ភារកិច្ច និងកិច្ចដំណើរការ នៃក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានរៀបចំធ្វើបច្ចុប្បន្នភាពសមាសភាពថ្មី នៃក្រុមការងារយុវជនគណបក្សប្រចាំក្រសួង
- បានរៀបចំធ្វើបច្ចុប្បន្នភាពក្រុមការងារយុវជន នៅតាមអង្គភាពនីមួយៗ ប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានបង្កើតនិងរៀបចំសមាសភាពលេខាធិការដ្ឋានរបស់ក្រុមការងារយុវជនគណបក្សប្រចាំក្រសួង
- បាននិងកំពុងរៀបចំធ្វើបច្ចុប្បន្នភាព និងបញ្ចូលសមាជិកថ្មីជាយុវជន របស់គណបក្សប្រចាំក្រសួង
- បានជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចល័ត ដើម្បីពង្រឹងល្បឿននិងប្រសិទ្ធភាពនៃទំនាក់ទំនងរវាងសមាជិកនៃក្រុមការងារយុវជនគណបក្សប្រចាំសាខាបក្ស និងប្រចាំក្រសួងទាំងមូល។

**ទី២. កិច្ចប្រជុំ ការងារផ្សព្វផ្សាយ និងការបណ្តុះបណ្តាល**

- បានរៀបចំពិធីសំណេះសំណាលរវាងក្រុមការងារយុវជនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាមួយក្រុមការងារយុវជនថ្នាក់កណ្តាល
- បានរៀបចំកម្មវិធីបទបថកថាស្តីពីសាវតារ, បុព្វហេតុ និងទស្សនវិស័យនយោបាយរបស់គណបក្សប្រជាជនកម្ពុជា
- បានចងក្រង និងផ្សព្វផ្សាយឯកសារគណបក្សសំខាន់ៗ ដូចជាកម្មវិធីនយោបាយ, គោលនយោបាយ, គោល-ការណ៍ និងសេចក្តីសម្រេចផ្សេងៗ ជូនសមាជិកក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួង។
- បានបញ្ជូនសមាជិកក្រុមការងារយុវជនគណបក្ស ទៅចូលរួមវគ្គអប់រំនយោបាយ តបតាមការអញ្ជើញរបស់គណៈឃោសនាអប់រំ នៃគណៈកម្មាធិការកណ្តាល។

បន្ថែមពីនេះ ដើម្បីបង្កើនការចូលរួម, ការយល់ដឹង, ឆន្ទៈ និងការគាំទ្រកម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា, លេខាធិការដ្ឋានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តួចផ្តើមរៀបចំផែនការយុទ្ធសាស្ត្រនៃការអភិវឌ្ឍយុវជនប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៣ ស្របនឹងកម្មវិធីនយោបាយរបស់គណៈបក្ស។ តាមរយៈការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍យុវជនគណបក្សប្រជាជន

DRAFT

កម្ពុជា ឆ្នាំ២០១៩-២០២៣ នឹងត្រូវបំពាក់ទាំងសមត្ថភាពជំនាញ និងមាគ៌ានយោបាយបន្ថែម, ការចែករំលែកបទពិសោធន៍ជីវភាពការងារ និងមេរៀននៃជីវិតពីឥស្សរជនជាន់ខ្ពស់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ព្រមទាំងមានឱកាសក្លាយជាវាគ្មិនឆ្នើមរបស់សាខាគណបក្សប្រជាជននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជារួម ផែនការយុទ្ធសាស្ត្រនៃការអភិវឌ្ឍយុវជនប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០៩-២០២៣ គឺជាឧបករណ៍ការងារគ្រប់ជ្រុងជ្រោយ និងជាមគ្គុទ្ទេសក៍ចង្អុលបង្ហាញផ្លូវសម្រាប់អនុវត្តរយៈពេលមធ្យម និងរយៈពេលវែង។ ក្នុងន័យនេះ យុទ្ធសាស្ត្រនេះ នឹងចង្អុលប្រាប់អំពីចក្ខុវិស័យ បេសកកម្ម និងប្រព័ន្ធគ្រប់គ្រងប្រកបដោយមហិច្ឆិតា និងមានភាពប្រាកដនិយម ដើម្បីបំពេញមុខងារយុវសេនាធិការឱ្យក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជា និងគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ ទន្ទឹមនេះ ខ្ញុំរំពឹងថា ផែនការយុទ្ធសាស្ត្រនេះ នឹងក្លាយជាឧបករណ៍គម្រូមួយដល់ក្រុមការងារយុវជនគណបក្សប្រជាជនប្រចាំក្រសួងស្ថាប័នផ្សេងទៀតផងដែរ ដើម្បីធ្វើការរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រគាំទ្រកម្មវិធីនយោបាយរបស់គណបក្សប្រជា-ជនកម្ពុជាប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ក្នុងនាមប្រធានក្រុមការងារយុវជនគណៈបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការ-ដ្ឋានក្រុមការងារយុវជនគណៈបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខ្ញុំសូមសម្តែងកតញ្ញូតាធម៌ដ៏ជ្រាល-ជ្រៅជូនឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** សមាជិកគណៈកម្មាធិការកណ្តាល និងជាប្រធានគណៈកម្មាធិការគណបក្សប្រជាជនយុវជនកម្ពុជា តែងតែផ្តល់មតិណែនាំ និងតម្រង់ទិស ដើម្បីធ្វើការរៀបចំនៃការអភិវឌ្ឍយុវជនប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៣។

ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១

**ប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជា**

**ប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត ហ៊ើល ចំរើន**

DRAFT

# មាតិកានុក្រម


បុព្វកថា … i

អារម្ភកថា … iii

I. សេចក្តីផ្តើម … 1

II. ចក្ខុវិស័យ, បេសកកម្ម និងគុណតម្លៃ … 3

ក. ចក្ខុវិស័យ … 3

ខ. បេសកកម្ម … 3

គ. គុណតម្លៃស្នូល … 4

III. រចនាសម្ព័ន្ធ និងការទទួលខុសត្រូវ … 5

IV. ការរៀបចំផែនការសកម្មភាពឆ្នាំ២០១៩-២០២២ និងយន្តការកៀរគរធនធានហិរញ្ញវត្ថុ … 7

ក. ការរៀបចំផែនការសកម្មភាព … 7

ខ. ប្រភពធនធានហិរញ្ញវត្ថុ … 7

V. យន្តការអនុវត្តផែនការសកម្មភាព និងត្រួតពិនិត្យលទ្ធផលសម្រេចបាន … 8

ក. យន្តការអនុវត្តផែនការសកម្មភាព … 8

ខ. យន្តការត្រួតពិនិត្យហិរញ្ញវត្ថុ និងសមិទ្ធកម្ម … 8

VI. សេចក្តីសន្និដ្ឋាន … 8

ឧបសម្ព័ន្ធ … 10

ឧបសម្ព័ន្ធ ក. ផែនការសកម្មភាពប្រចាំឆ្នាំ ២០១៩ … 11

ឧបសម្ព័ន្ធ ខ. ផែនការសកម្មភាពរយៈពេលមធ្យមឆ្នាំ២០១៩-២០២៣ … 17

ឧបសម្ព័ន្ធ គ. សមិទ្ធផលសម្រេចបានឆ្នាំ២០១៣-២០១៨ … 21

ឧបសម្ព័ន្ធ ឃ.ទម្រង់រៀបចំផែនការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ និង រយៈពេលមធ្យម … 26

ឧបសម្ព័ន្ធ ង. ទម្រង់របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងប្រចាំឆ្នាំ … 31

ឧបសម្ព័ន្ធ ច. ទម្រង់របាយការណ៍សមិទ្ធកម្មពាក់កណ្តាលឆ្នាំ និងប្រចាំឆ្នាំ … 35

ឧបសម្ព័ន្ធ ឆ. សេចក្តីកំណត់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ … 38

ឧបសម្ព័ន្ធ ជ. សេចក្តីកំណត់ស្តីពីការកែសម្រួលប្រការ ៦ នៃសេចក្តីកំណត់លេខ ៣៦/១៤ គប.ក សហវ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ … 43


DRAFT

ឧបសម្ព័ន្ធ ឈ.សេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ........................................................46
ឧបសម្ព័ន្ធ ញ. សេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពបន្ថែមក្នុងក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ.......................................49
ឧបសម្ព័ន្ធ ដ. សេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពលេខាធិការដ្ឋាននៃក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ .................................52
ឧបសម្ព័ន្ធ ឋ. សេចក្តីសម្រេចស្តីពីការទទួលស្គាល់សមាសភាពយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ........................................................................55

DRAFT

## I. សេចក្ដីផ្ដើម

គណបក្សប្រជាជនកម្ពុជា បានបដិសន្ធិឡើងនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១។ គណបក្សប្រជាជនកម្ពុជាប្រកាន់ខ្ជាប់ឧត្តមគតិស្នេហាជាតិ, ហ៊ានធ្វើពលីកម្មគ្រប់យ៉ាងដើម្បីប្រយោជន៍ប្រទេសជាតិ និងប្រជាជន និង ខិតខំបង្រួបបង្រួមប្រមូលផ្តុំកម្លាំងរបស់ជាតិទាំងមូល ដើម្បីកសាងប្រទេសកម្ពុជា ឯករាជ្យ សន្តិភាព ប្រជាធិបតេយ្យ អព្យាក្រឹត្យ និងវឌ្ឍនភាពសង្គម។ ក្នុងន័យនេះ គណបក្សប្រជាជនកម្ពុជា គឺរបស់ប្រជាជន បានស្ថិតស្ថេរ និងរីកចម្រើនអាស្រ័យដោយប្រជាជន និងធ្វើអ្វីៗ គ្រប់យ៉ាង ដើម្បីឧត្តមប្រយោជន៍របស់ជាតិ និងប្រជាជន។ ក្នុងការបំពេញបេសកកម្មជាប្រវត្តិសាស្ត្ររបស់ខ្លួន គណបក្សប្រជាជនកម្ពុជា មានគោលដៅចំបងជាយុទ្ធសាស្ត្រយូរអង្វែងដែលត្រូវពុះពារសម្រេចឱ្យបានគឺ÷

- កសាងប្រទេសជាតិឱ្យជឿនលឿន មានវឌ្ឍនភាពខ្លាំងក្លាលើគ្រប់វិស័យ មានសាមគ្គីភាពរឹងមាំ មានការគោរពសិទ្ធិមនុស្ស តម្លៃសីលធម៌ សមធម៌ សេរីភាព និងយុត្តិធម៌ មានលទ្ធិប្រជាធិបតេយ្យដែលចាក់គ្រឹះរឹងមាំ ធ្វើឱ្យប្រជាជនបានរស់នៅប្រកបដោយសុភមង្គល សុខដុមរមនា ទាំងក្នុងគ្រួសារ ទាំងក្នុងសហគមន៍ ដ៏ដូចជាសង្គមជាតិទាំងមូល
- ការពារប្រទេសជាតិឱ្យស្ថិតស្ថេរគង់វង្សក្នុងឯករាជ្យ សន្តិភាព អធិបតេយ្យ និងបូរណភាពទឹកដីដ៏ពេញលេញរបស់ខ្លួនថែរក្សារដ្ឋធម្មនុញ្ញនិងរាល់សមិទ្ធផលនៃសង្គមជាតិលើកតម្កើងកិត្យានុភាពជាតិនុភាពឱ្យបានខ្ពស់ឡើងជានិច្ច។

ក្នុងន័យនេះ, សុខសន្តិភាពដែលប្រជាជនកម្ពុជាបាននិងកំពុងអាស្រ័យផលរយៈពេលជិត ២ទសវត្សរ៍ចុងក្រោយនេះ គឺជាមហាសមិទ្ធិ ដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ដែលយុវជនកម្ពុជាជំនាន់មុន បានស្ថាបនាឡើងដោយការលះបង់គ្រប់បែបយ៉ាង រួមទាំងអាយុជីវិតផ្ទាល់ខ្លួន និងសេចក្តីសុខក្នុងគ្រួសារផង។ ចាប់តាំងពីនៅក្នុងដំណាក់កាលដែលប្រទេសកម្ពុជាស្ថិតក្នុងស្ថានភាពមានសន្តិភាពផង និងមានសង្គ្រាមផងមកម្ល៉េះថ្នាក់ដឹកនាំនិងយុវជនជំនាន់មុន, ជាពិសេស គឺ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ផ្ទាល់តែម្តង, បានយល់ដឹងច្បាស់និងប្រកាន់ខ្ជាប់រួចទៅហើយថា ការងារកែទម្រង់គឺជាកិច្ចការស្លាប់-រស់ របស់ប្រទេសជាតិ ដែលត្រូវតែធ្វើ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។ ជាក់ស្តែង នៅក្រោមការដឹកនាំប្រកបដោយភាពវៃឈ្លាស, ប្រាកដនិយម, ពោរពេញដោយភាពក្លាហាន, គតិបណ្ឌិត ព្រមទាំងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អគ្គហារដ្ឋបុរសនៃយើង កម្ពុជាបានចាប់ប្រកាន់យកនូវការកែទម្រង់ជាបន្តបន្ទាប់ ឥតរាថយឡើយ ដោយចាប់ផ្តើមពីការបញ្ចប់ភាពអត់ឃ្លានដ៏រ៉ាំរ៉ៃ ក្រោយការរំដោះប្រទេសជាតិ ៧ មករា ១៩៧៩ និងបានឆ្លងកាត់ការកែទម្រង់របបសេដ្ឋកិច្ចជាតិ ពីសេដ្ឋកិច្ចផែនការ មកជា សេដ្ឋកិច្ចទីផ្សារ នៅក្នុងខណៈដែលស្ថាប័ននយោបាយរបស់យើង កំពុងស្ថិតក្នុងស្ថានភាពផ្លាស់ប្តូរជាបណ្តើរៗ និងបានបន្តរហូតមកដល់ការដាក់ឱ្យដំណើរការកម្មវិធីកែទម្រង់គ្រប់ជ្រុងជ្រោយ ទៅតាមអភិក្រមគ្របដណ្តប់តាមវិស័យ ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិនាពេលបច្ចុប្បន្ននេះ។

ពិនិត្យជារួម, សាវតារនៃការដឹកនាំកសាងខឿនសេដ្ឋកិច្ចកម្ពុជា តាំងពីក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩ មកទល់បច្ចុប្បន្ននេះ កម្ពុជាឆ្លងកាត់បណ្តាដំណាក់កាលដ៏លំបាកស្មុគស្មាញជាបន្តបន្ទាប់, កម្ពុជាសម្រេចបាននូវការផ្លាស់ប្តូរមុខមាត់ថ្មីដ៏គួរជាទីមោទនៈបំផុត។ កម្ពុជា ដែលពីមុនល្បីថា ជាវាលពិឃាត, ជាតំបន់អសន្តិសុខ, ជាចម្ការមីនដែលគេភ័យខ្លាចគ្រប់គ្នា, ឥឡូវនេះ បានក្លាយទៅជា "**កោះសន្តិភាព**" និង ជាតំបន់ទេសចរណ៍ប្រកបដោយប្រជាប្រិយភាពនៅ

DRAFT

ក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលទទួលបានភ្ញៀវទេសចរណ៍រាប់លាននាក់ក្នុងមួយឆ្នាំ។ កម្ពុជា ដែលពីមុនល្បីក្នុងការប្រើ-ប្រាស់អាវុធដើម្បីដណ្តើមអំណាចគ្នា និង ក្នុងការផ្លាស់ប្តូររាជរដ្ឋាភិបាល, ឥឡូវនេះ បានក្លាយទៅជាប្រទេសដែលរៀបចំយ៉ាងទៀងទាត់ នូវការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដើម្បីឱ្យប្រជាពលរដ្ឋជ្រើសតាំងតំណាងដឹកនាំប្រទេស, ជានីតិរដ្ឋដែលគោរពគោលការណ៍ច្បាប់ដោយឥតងាករេ និង ជារដ្ឋអធិបតេយ្យ ដែលមានបូរណភាពទឹកដីពេញលេញ។ កម្ពុជា ដែលពីមុនជាប្រទេសត្រូវទទួលរងការហ៊ុមព័ទ្ធ និង ឯកោ ទាំងខាងនយោបាយ និង សេដ្ឋកិច្ច, ឥឡូវនេះ បានក្លាយជាប្រទេសមួយដែលកំពុងសមាហរណខ្លួនយ៉ាងសកម្ម ទៅក្នុងរចនាសម្ព័ន្ធ និង និម្មាបនកម្មតំបន់ និង ពិភពលោក និងជាប្រទេសដែលកំពុងដើរតួយ៉ាងសកម្ម ដោយស្មើសិទ្ធិ និងស្មើភាព ក្នុងគ្រប់កិច្ចការតំបន់ និង នៅលើឆាកអន្តរជាតិ។ កម្ពុជា ដែលពីមុនជាប្រទេសអន់ថយខាងផ្នែកសេដ្ឋកិច្ច, គ្របដណ្តប់ទៅដោយភាពក្រីក្រ និង មានអសន្តិសុខស្បៀង, ឥឡូវនេះ បានក្លាយជាប្រទេសនាំស្បៀងចេញ, ហើយស្ថិតនៅក្នុងចំណោមប្រទេសឯតទគ្គៈលើពិភពលោក ដែលបានសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ និងជាប្រទេសដែលសម្រេចបាននូវវឌ្ឍនភាពដ៏ល្អប្រសើរក្នុងការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាការកែលម្អសូចនាករផ្នែកសង្គមកិច្ច ហើយបានឆ្លងកាត់ដោយជោគជ័យ ពីចំណាត់ថ្នាក់នៃប្រទេសមានចំណូលទាបក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប កាលពីពេលថ្មីៗកន្លងទៅ ។

សមិទ្ធផលដែលយើងសម្រេចបាននាពេលកន្លងមក បានចង្អុលប្រាប់យ៉ាងប្រត្យក្សថា ការកែទម្រង់គឺជាមាគ៌ាដ៏ត្រឹមត្រូវតែមួយគត់ ដែលយើងបានសម្រេចជ្រើសរើសយកមកប្រតិបត្តិដោយឥតងាករេ និងម៉ឺងម៉ាត់ក្លៀវក្លា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត បញ្ញាញាណវាងវៃ និងចក្ខុវិស័យវែងឆ្ងាយរបស់ អគ្គមហារដ្ឋបុរស នៃយើង គឺ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងន័យនេះ ការយល់ដឹងរបស់យុវជន អំពីការងារកែទម្រង់របស់រាជរដ្ឋាភិបាល គឺជាលក្ខខណ្ឌសម្រាប់ធានានិរន្តរភាពនិងចីរភាពនៃការអភិវឌ្ឍប្រទេសជាតិ ពីមួយជំនាន់ទៅកាន់មួយជំនាន់ទៀត ជាបន្តបន្ទាប់ ការឈានទៅមុខ ជាពិសេសចក្ខុវិស័យប្រែក្លាយកម្ពុជាទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ទន្ទឹមនឹងទស្សនវិស័យដែលកំណត់ថា ការកែទម្រង់គឺជាគន្លឹះជោគជ័យនៃការអភិវឌ្ឍស្ថាប័ន ប្រកបដោយនិរន្តរភាព និងចីរភាព។

ដើម្បីគាំទ្រកម្មវិធីនយោបាយគណបក្សប្រជាជនកម្ពុជាឱ្យអនុវត្តបានប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព, គណៈកម្មាធិការបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្កើតឱ្យមានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬហៅកាត់ថា **ក.យ.ក.** តាមរយៈសេចក្តីសម្រេចលេខ ១២.១២ គប/កសហវ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ និងលេខាធិការដ្ឋាន **ក.យ.ក.** ដែលកាលនោះយុវជនគណបក្ស មានឈ្មោះថា "សកម្មជនយុវជនគណបក្ស"។ នៅក្នុងនីតិកាលទី៥ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** សមាជិកគណៈ-កម្មាធិការកណ្តាល និងប្រធានគណៈកម្មាធិការគណបក្សក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានពិនិត្យ និងកែសម្រួលក្រុមការងារយុវជនគណបក្សប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឡើងវិញ ឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រងនិងការទទួលខុសត្រូវកាន់តែច្បាស់លាស់ ដើម្បីឆ្លើយតបនឹងតម្រូវការកម្លាំងយុវជនសម្រាប់គាំទ្រសកម្មភាព និងជំរុញដណ្តើមប្រៀបឈ្នះជូនគណបក្ស។ ទន្ទឹមនេះ **ក.យ.ក.** គឺមាននៅតាមសាខាបក្សអគ្គលេខាធិការដ្ឋាន, អគ្គនាយកដ្ឋាន, អគ្គាធិការដ្ឋាន និងវិទ្យា

DRAFT

ស្ថានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាប្រសិទ្ធភាពការអនុវត្តការងារ និងគាំទ្រកម្មវិធីនយោបាយរបស់គណបក្ស។ នាពេលបច្ចុប្បន្ននេះ **គ.យ.គ.** គឺដឹកនាំដោយឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** ជាប្រធាន និងមានសមាជិកជាច្រើនរូប រីឯលេខាធិការដ្ឋាន **គ.យ.គ.** ដឹកនាំដោយឯកឧត្តម **យ៉េត វីរណៈល** ប្រធាន និងមានសមាជិកជច្រើនរូបទៀត។

លេខាធិការដ្ឋាន **គ.យ.គ.** បំពេញមុខងាររបស់ខ្លួនជាសេនាធិការប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព ជូនក្រុមការងារយុវជនគណបក្សប្រជាជនប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការចាត់តាំងណាមួយ។

## II. ចក្ខុវិស័យ, បេសកកម្ម និងគុណតម្លៃ

### ក. ចក្ខុវិស័យ

លេខាធិការដ្ឋាន **គ.យ.គ.** បានកំណត់ និងដាក់ចេញនូវចក្ខុវិស័យ និងច្បាស់លាស់ គឺយុវជនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាកម្លាំងសាមគ្គី ស្មោះស្ម័គ្រភក្តី ថ្លៃថ្នូរ និងរឹងមាំ ដើម្បីឧត្តមប្រយោជន៍ជាតិ និងប្រជាពលរដ្ឋ។ បន្ថែមពីលើនេះ, ផែនការយុទ្ធសាស្ត្រនេះ គឺជាឧបករណ៍ការងារគ្រប់ជ្រុងជ្រោយ ជាមគ្គុទេសក៍ និងជាផែនទីបង្ហាញផ្លូវក្នុងរយៈពេលប្រាំឆ្នាំរបស់លេខាធិការដ្ឋានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលក្នុងគោលបំណងបម្រើផលប្រយោជន៍ និងលើកតម្កើងប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តក្រុមការងារយុវជនកម្ពុជា ដើម្បីបុព្វហេតុចូលរួមបម្រើជាឧត្តមប្រយោជន៍នៃសង្គមជាតិ។

### ខ. បេសកកម្ម

ដើម្បីសម្រេចបានតាមចក្ខុវិស័យដ៏ថ្លៃថ្លាដូចបានកំណត់ខាងលើ លេខាធិការដ្ឋាន **គ.យ.គ.** គឺផ្តល់កាលានុវត្តភាពជូនយុវជន សម្រេចសក្តានុពលរបស់ខ្លួន ជាប្រយោជន៍ដល់ការអនុវត្តគោលនយោបាយរបស់គណបក្សនិងរាជរដ្ឋាភិបាល ក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទន្ទឹមនេះ ដើម្បីបំពេញបេសកកម្មដ៏មុះមុត និងក្លៀវក្លានេះ បេសកកម្មត្រូវបានបែងចែកចេញជាបីគោលបំណង រួមមាន÷ (១). បំពាក់បំប៉នស្មារតីគណបក្សជូនក្រុមការងារយុវជននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំងផ្នែកនយោបាយ និងបច្ចេកទេសពាក់ព័ន្ធលើការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, (២). ផ្សព្វផ្សាយកម្មវិធីនយោបក្សប្រជាជន រួមទាំងសមិទ្ធផលរបស់គណបក្ស ប្រកបដោយភាពច្បាស់លាស់ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដើម្បីគាំទ្រសមាជិកក្រុមការងារថ្នាក់មូលដ្ឋាន និងប្រជាជនមានទំនុកចិត្តបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា និង (៣). គាំទ្រនិងសម្របសម្រួលជាមួយសាខាក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីអនុវត្តផែនការសកម្មភាពប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធភាព។ តាមរយៈការសម្រេចបានបេសកកម្មនេះ លេខាធិការដ្ឋាន **គ.យ.គ.** នឹងមានលទ្ធភាពធ្វើការកៀរគរយុវជននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យគាំទ្រកម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា និងបោះឆ្នោតជូនគណបក្សប្រជាជន កម្ពុជា ដើម្បីបុព្វហេតុសន្តិភាព និងការអភិវឌ្ឍ។

តារាងទី១÷ សេចក្តីសង្ខេបទស្សនាទានរបស់លេខាធិការដ្ឋានយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំ កសហវ

| ទស្សនាទាន | | ពិពណ៌នា |
|---|---|---|
| **ចក្ខុវិស័យ** | | យុវជនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាកម្លាំងសាមគ្គី ស្មោះស្ម័គ្រភក្តី ថ្លៃថ្នូរ និងរឹងមាំ ដើម្បីឧត្តមប្រយោជន៍ជាតិ និងប្រជាពលរដ្ឋ។ |
| **បេសកកម្ម** | | ផ្តល់កាលានុវត្តភាពជូនយុវជន សម្រេចសក្តានុពលរបស់ខ្លួន ជាប្រយោជន៍ដល់ការអនុវត្តគោលនយោបាយរបស់គណបក្សនិងរាជរដ្ឋាភិបាល ក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |
| **គោលបំណង** | **ទីមួយ** | បំពាក់បំប៉នស្មារតីគណបក្សជូន **គ.យ.គ.** ទាំងផ្នែកនយោបាយ និងបច្ចេកទេសពាក់ព័ន្ធលើការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |
| | **ទីពីរ** | ផ្សព្វផ្សាយកម្មវិធីនយោបក្សប្រជាជន រួមទាំងសមិទ្ធផលរបស់គណបក្ស ប្រកបដោយភាពច្បាស់លាស់ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដើម្បីគាំទ្រសមាជិកក្រុមការងារថ្នាក់មូលដ្ឋាន និងប្រជាជនមានទំនុកចិត្តបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា។ |
| | **ទីបី** | គាំទ្រ និងសម្របសម្រួលជាមួយសាខាក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីអនុវត្តផែនការសកម្មភាពប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធភាព។ |

### គ. គុណតម្លៃស្នូល

**គ.យ.គ.** ត្រូវបំពាក់ចំណេះដឹង, ជំនាញ និងក្រមសីលធម៌ ដើម្បីឱ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានឆន្ទៈមុះមុត ថាពិតជាស្នេហា និងគាំទ្រមាគ៌ានយោបាយគណបក្សប្រជាជនកម្ពុជា។ បន្ថែមពីនេះ **គ.យ.គ.** ត្រូវមានគុណតម្លៃដូចតទៅ÷

- **វិជ្ជាជីវភាព** : ការបំពេញការងារប្រកបដោយលក្ខណៈវិជ្ជាជីវៈ និងមិនត្រូវមើលបំណាំគ្នា ព្រមទាំងត្រូវមានចំណេះដឹង ចំណេះធ្វើ ចេះពិចារណា និងឆ្លើយតបចំពោះសំណូមពរការងារ និងហេតុការផ្សេងបានឆាប់រហ័ស និងបំពេញការងារជាសមូហភាព។ បន្ថែមពីនេះ ត្រូវបំពេញការងារប្រកបដោយទិសដៅច្បាស់លាស់ និងភាពជាគម្រូ។
- **ការពង្រឹងស្មារតីពុះពារអប់រំកសាងខ្លួនជាប្រចាំ** : មានសមត្ថភាពជំនាញកម្រិតខ្ពស់ និងត្រូវបំពាក់បំប៉ន និងរៀនសូត្រកម្មវិធីនយោបាយគណបក្ស ជាប្រចាំតាមរយៈការចូលរួមការអនុវត្តតាមផែនការសកម្មភាពដែលដាក់ចេញ។
- **គុណធម៌** : ការបំពេញជីវភាពការងារ, ជីវភាពរស់នៅ និងការទំនាក់ទំនងជាមួយមហាជនប្រកបដោយគុណធម៌។
- **សីលធម៌** : ការបំពេញការងារប្រកបដោយសីលធម៌ ពោលគឺយុវជនត្រូវចេះគោរពគ្នា និងអធ្យាស្រ័យទៅវិញទៅមក និងមិនត្រូវមើលរំលងកំហុសរបស់ខ្លួនឯង។
- **វិន័យ** : អនុវត្តបាននូវវិន័យក្នុងការបំពេញការងាររបស់ខ្លួន ស្របតាមលក្ខន្តិកៈគណបក្សប្រជាជនកម្ពុជា។
- **ថែរក្សាសាមគ្គីភាព, ភាពស្មោះត្រង់ និងការរក្សាសម្ងាត់** : ឯកភាពផ្ទៃក្នុងឱ្យបានរឹងមាំ និងអនុវត្តរាល់សេចក្តីសម្រេចរបស់គណបក្សកម្ពុជា។ ការអនុវត្តផែនការប្រតិបត្តិគឺត្រូវស្របតាមកម្មវិធីនយោបាយរបស់បក្ស និងបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា ដើម្បីបុព្វហេតុសន្តិភាព និងការអភិវឌ្ឍ។ បន្ថែមពីនេះ រាល់ព័ត៌មាន ឬឯកសារសំងាត់របស់គណបក្សគឺមិនត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ទេ។

DRAFT

## III. រចនាសម្ព័ន្ធ និងការទទួលខុសត្រូវ

ដើម្បីបំពេញមុខងារ និងដំណើរការនៃគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព, រចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រងត្រូវបានរៀបចំតាមលំដាប់ ដូចតទៅ÷

**ទី១. ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានបង្កើតដោយសេចក្តីសម្រេចលេខ០២/១៨ គ.ប.កសហវ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការទទួលស្គាល់សមាសភាពយុវជនជាសមាជិកគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានអាយុចាប់ពី១៨ ដល់ ៤០ ឆ្នាំ ដែលសរុបមានចំនួន ២១៣៧ នាក់ ក្នុងនោះស្រី ៧១៥ នាក់។ សមាសភាពយុវជនសមាជិកគណបក្សប្រជាជនកម្ពុជាពីគ្រប់សាខាបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានបញ្ជាក់លម្អិតនៅក្នុងឧបសម្ព័ន្ធ **៣** ។

ជារួម ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសមាសភាពមកពីគ្រប់សាខាបក្សប្រជាជនកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានចំនួនដូចបានរៀបរាប់ខាងក្រោម÷

១. គណៈកម្មាធិការសាខាបក្ស នៃក្រុមប្រឹក្សាជាតិគណនេយ្យ មានចំនួន ៣៩ រូប

២. គណៈកម្មាធិការសាខាបក្ស នៃខុទ្ទកាល័យ មានចំនួន ៤ រូប

៣. គណៈកម្មាធិការសាខាបក្ស នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានចំនួន ១៨២ រូប

៤. គណៈកម្មាធិការសាខាបក្ស នៃអគ្គនាយកដ្ឋានពន្ធដារ មានចំនួន ៨៨១ រូប

៥. គណៈកម្មាធិការសាខាបក្ស នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានចំនួន ២២០ រូប

៦. គណៈកម្មាធិការសាខាបក្ស នៃអគ្គនាយកដ្ឋានរតនាគារជាតិ មានចំនួន ៨៧ រូប

៧. គណៈកម្មាធិការសាខាបក្ស នៃអគ្គនាយកដ្ឋានគោលនយោបាយ មានចំនួន ៦៥ រូប

៨. គណៈកម្មាធិការសាខាបក្ស នៃអគ្គនាយកដ្ឋានថវិកា មានចំនួន ៦២ រូប

៩. គណៈកម្មាធិការសាខាបក្ស នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ មានចំនួន ៣៤ រូប

១០. គណៈកម្មាធិការសាខាបក្ស នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មានចំនួន ៦១

១១. គណៈកម្មាធិការសាខាបក្ស នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធមានចំនួន ៤២ រូប

១២. គណៈកម្មាធិការសាខាបក្សនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ មានចំនួន ៦៨ រូប

១៣. គណៈកម្មាធិការសាខាបក្ស នៃអគ្គាធិការដ្ឋានមានចំនួន ២៤ រូប

១៤. គណៈកម្មាធិការសាខាបក្ស នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ១៧ រូប

១៥. គណៈកម្មាធិការសាខាបក្ស នៃអគ្គនាយកដ្ឋានដោះស្រាយគម្រោងដោយសារគម្រោងអភិវឌ្ឍន៍មានចំនួន ២៣ រូប

DRAFT

១៦. គណៈកម្មាធិការសាខាបក្ស នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល មានចំនួន ៤៣ រូប

១៧. គណៈកម្មាធិការសាខាបក្ស នៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានចំនួន ៤៣ រូប

១៨. គណៈកម្មាធិការសាខាបក្ស នៃគណៈកម្មការមូលបត្រកម្ពុជា មានចំនួន ១៣២ រូប

១៩. គណៈកម្មាធិការសាខាបក្ស នៃក្រុមហ៊ុនធានារ៉ាប់រងកម្ពុជា "រី" មានចំនួន ០៥ រូប

២០. គណៈកម្មាធិការសាខាបក្ស នៃធនាគារអភិវឌ្ឍន៍ជនបទ មានចំនួន ៦៣ រូប

២១. គណៈកម្មាធិការសាខាបក្ស នៃផ្សារមូលបត្រកម្ពុជាមានចំនួន ៣៧ រូប។

**ទី២.លេខាធិការដ្ឋានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជា គឺមានលេខាធិការដ្ឋាន **ក.យ.ក.** ជាយុវសេនាធិការមួយដ៏រឹងរាំ ដោយប្រមូលផ្តុំយុវជនដែលមានសមត្ថភាព និងពុទ្ធិ ដើម្បីរួមចំណែក និងគាំទ្រ ទាំងការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការអនុវត្តកម្មវិធីនយោបាយរបស់គណបក្ស។ លេខាធិការដ្ឋាន **ក.យ.ក.** បានរៀបចំនូវអង្គចាត់តាំង និងការទទួលខុសត្រូវច្បាស់លាស់ ដើម្បីសម្រេចឱ្យបាននូវការអនុវត្តផែនការយុទ្ធសាស្ត្រ ដូចតទៅ÷

១. ឯកឧត្តមបណ្ឌិត **ហ៊ើល ចំរើន** ប្រធាន **ក.យ.ក.** ទទួលទន្ទុកលើ **ចក្ខុវិស័យ**

២. ឯកឧត្តម **យ៉េត វីណែល** ប្រធានលេខាធិការដ្ឋាន **ក.យ.ក.** ទទួលទន្ទុកលើ **បេសកកម្ម**

៣. ឯកឧត្តម **ស៊ាង ផល្លា** អនុប្រធានលេខាធិការដ្ឋាន **ក.យ.ក.** ទទួលទន្ទុកអនុវត្ត **គោលបំណងទី១**

៤. លោក **អ៊ុក សុផា** អនុប្រធានលេខាធិការដ្ឋាន **ក.យ.ក.** ទទួលទន្ទុកអនុវត្ត **គោលបំណងទី២**

៥. លោក **អ៊ុំ យុទ្ធី** អនុប្រធានលេខាធិការដ្ឋាន **ក.យ.ក.** ទទួលទន្ទុកអនុវត្ត **គោលបំណងទី៣**

៦. លោក **លី ទ៉ុង** អនុប្រធានលេខាធិការដ្ឋាន **ក.យ.ក.** ទទួលទន្ទុកសម្របសម្រួលការអនុវត្ត និងបូកសរុបនៃលទ្ធផលនៃការអនុវត្តផែនការប្រតិបត្តិ និងផែនការយុទ្ធសាស្ត្រនៃការអភិវឌ្ឍយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំ កសហវ ឆ្នាំ២០១៨-២០២០។

សមាសភាពលេខាធិការដ្ឋាន **ក.យ.ក.** មានបញ្ជាក់លម្អិតក្នុងឧបសម្ព័ន្ធ **៣** ។

DRAFT

ដ្យាក្រាមទី១÷ រចនាសម្ព័ន្ធ នៃលេខាធិការដ្ឋាន **គ.យ.គ.**




## IV. ការរៀបចំផែនការសកម្មភាពឆ្នាំ២០១៩-២០២៣ និងយន្តការគៀរគរធនធានហិរញ្ញវត្ថុ

### ក. ការរៀបចំផែនការសកម្មភាព

ផែនការយុទ្ធសាស្ត្ររបស់លេខាធិការដ្ឋាន **គ.យ.គ.** ត្រូវបានរៀបចំឡើងឱ្យមានសមានគតិភាព និងសង្គតិភាពជាមួយគោលបំណង, បេសកកម្ម និងចក្ខុវិស័យ។ ទាំងផែនការយុទ្ធសាស្ត្រ និងទាំងផែនការសកម្មភាពគឺត្រូវបានរៀបចំឡើងស្របតាមប្រតិទិនប្រចាំឆ្នាំ ដូចមានបែងចែក ដូចខាងក្រោម÷

- ដំណាក់កាលទី១ ក្នុងកំឡុងខែតុលា ÷ រៀចំផែនការសកម្មភាព និងគ្រោងថវិកា
- ដំណាក់កាលទី២ ក្នុងកំឡុងខែវិច្ឆិកា÷ រៀបចំកិច្ចប្រជុំពិភាក្សាស្តីពីផែនការការសកម្មភាព និងគ្រោងថវិកាក្នុងកម្រិតលេខាធិការដ្ឋាន **គ.យ.គ.**
- ដំណាក់កាលទី៣ ក្នុងកំឡុងខែធ្នូ÷ ផែនការសកម្មភាពត្រូវដាក់ជូនថ្នាក់ដឹកពិនិត្យ និងអនុម័ត។

ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ និងរយៈពេល៥ ឆ្នាំត្រូវបានរៀបចំតាមទម្រង់ក្នុងឧបសម្ព័ន្ធ ឃ។

### ខ. ប្រភពធនធានហិរញ្ញវត្ថុ

ស្របតាមបទបញ្ជាផ្ទៃក្នុងរបស់គណបក្សប្រជាជនកម្ពុជា និងសេចក្តីកំណត់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមការងារយុវជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីប្រភពហិរញ្ញវត្ថុ, លេខាធិការដ្ឋាន **គ.យ.គ.** ធ្វើការគៀរគរប្រភពធនធាន ដើម្បីអនុវត្តផែនការសកម្មភាពរយៈពេលមធ្យម និងរយៈពេលវែង រួមមាន÷

១. វិភាគទានរបស់គណៈកម្មាធិការគណបក្សក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

DRAFT

២. វិភាគទានរបស់គណៈកម្មាធិការសាខាបក្ស នៅតាមអគ្គលេខាដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធ
៣. វិភាគទាន ឬភាគទានរបស់ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងនៅតាមអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធ
៤. វិភាគទានរបស់សប្បុរសជននានា
៥. ការឧបត្ថម្ភរបស់គណបក្សប្រជាជនកម្ពុជា។

លេខាធិការដ្ឋាន **គ.យ.ក.** ត្រូវរៀបចំគម្រោងអំពីតម្រូវការធនធានហិរញ្ញវត្ថុប្រចាំឆ្នាំ និងរយៈពេលមធ្យម។

ការរៀបចំផែនការយុទ្ធសាស្ត្រ, ផែនការសកម្មភាព និងការគ្រោងប្រភពធនធានហិរញ្ញវត្ថុ ជាកម្មវត្ថុនៃការសម្រួលប្រចាំឆ្នាំ ដើម្បីឱ្យស្របតាមបរិបទនៃស្ថានភាពនយោបាយ និងការវិវឌ្ឍនៃស្ថានភាពសង្គម-សេដ្ឋកិច្ច។

## V. យន្តការអនុវត្តផែនការសកម្មភាព និងត្រួតពិនិត្យលទ្ធផលសម្រេចបាន

### ក. យន្តការអនុវត្តផែនការសកម្មភាព

ដើម្បីធ្វើការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ លេខាធិការដ្ឋាន **គ.យ.ក.** ត្រូវធ្វើការស្នើសុំមកប្រធានក្រុមការងារ **គ.យ.ក.** ដើម្បីធ្វើការពិនិត្យ និងសម្រេច។ ក្នុងករណី មានការយល់ស្របលើសំណើនៃការអនុវត្តផែនការសកម្មភាពត្រូវដាក់ជូនថ្នាក់ដឹកនាំគណបក្សប្រជាជនប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ខ. យន្តការត្រួតពិនិត្យហិរញ្ញវត្ថុ និងសមិទ្ធកម្ម

- **របាយការណ៍ស្តីពីការអនុវត្តហិរញ្ញវត្ថុ**

លេខាធិការដ្ឋាន **គ.យ.ក.** ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស, ពាក់កណ្តាលឆ្នាំ និងប្រចាំឆ្នាំ ដោយបង្ហាញនូវធនធានហិរញ្ញវត្ថុ, ការចំណាយ និងសមតុល្យ ដើម្បីគោរពរាយការណ៍ជូនប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជាប្រចាំ កសហវ។ ទម្រង់របាយការណ៍ហិរញ្ញវត្ថុ គឺក្នុងឧបសម្ព័ន្ធ **ខ**។

- **របាយការណ៍សមិទ្ធកម្ម**

លេខាធិការដ្ឋាន **គ.យ.ក.** ត្រូវធ្វើការរៀបចំរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពពាក់កណ្តាលឆ្នាំ និងប្រចាំឆ្នាំ ស្របតាមទម្រង់ក្នុងឧសម្ព័ន្ធទី **ច**។

**បញ្ជាក់÷** របាយការណ៍សមិទ្ធកម្ម និងរបាយការណ៍ហិរញ្ញវត្ថុទាំងពាក់កណ្តាលប្រចាំឆ្នាំ និងប្រចាំឆ្នាំ ត្រូវបានរៀបចំដំណាលគ្នា និងដាក់ជូនថ្នាក់ដឹកនាំគណៈកម្មាធិការគណបក្សប្រជាជនប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការពិនិត្យនិងសម្រេច ឬផ្តល់ការណែនាំដើម្បីអនុវត្តផែនការសកម្មភាពបន្ត ឬដាក់ជាវិធានការជាក់លាក់ណាមួយ។

## VI. សេចក្តីសន្និដ្ឋាន

ក្នុងស្មារតីការពារខ្ជាប់ខ្ជួននូវបុព្វហេតុទាំងពីរ រួមមាន សន្តិភាព និងការអភិវឌ្ឍ ព្រមទាំងគាំទ្រកម្មវិធីនយោបាយ-គណបក្សប្រជាជនកម្ពុជា, លេខាធិការដ្ឋាន **គ.យ.ក.** ខិតខំបំពេញមុខងារជាសេនាធិការ ប្រកបដោយសកម្ម, បុរេសកម្ម និងអន្តរសកម្ម ដើម្បីសម្រេចនូវចក្ខុវិស័យ និងបេសកម្ម ដ៏ថ្លៃថ្លានេះ។ លេខាធិការដ្ឋាន **គ.យ.ក.** ប្តេជ្ញាអនុវត្តផែនការ



DRAFT

យុទ្ធសាស្ត្រនៃការអភិវឌ្ឍយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០១៨-២០២៣ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដែលយុវជននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងទទួលបាននូវ÷ ទី១. យល់ស៊ីជម្រៅអំពីកម្មវិធីនយោបាយ, សាវតារ, បុព្វហេតុ និង ទស្សនវិស័យនយោបាយរបស់គណបក្សប្រជាជនកម្ពុជា ព្រមទាំងបង្កើនភាពជាអ្នកដឹកនាំ និងមានគំនិតផ្តួចផ្តើម, ទី២. យុវជនមានស្មារតីដ៏រឹងមាំបំផុតនៃការជឿជាក់ និងការគាំទ្រដ៏ពិតប្រាកដឥតងាករេ មកលើគណបក្ស និងបង្កើនសក្តានុពលភាពយុវជនសកម្មជនរបស់គណបក្ស និងទី៣. យុវជនមានឱកាសទទួលបានការចែករំលែកបទពិសោធន៍ស្តីពីជីវភាពការងារ និងជីវិតផ្ទាល់របស់ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្ទាល់ និងថ្នាក់ដឹកនាំនៃស្ថាប័នរាជរដ្ឋាភិបាល។

សរុបសេចក្តីមក លេខាធិការដ្ឋាន **គ.យ.គ.** ប្រកាន់នូវការសហការគ្នាយ៉ាងស្អិតល្មួតនៃក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលឆ្លុះបញ្ចាំងកំលាំងស្នូល និងកំលាំងពិត។ តាមរយៈនេះ ទំនាក់-ទំនងរវាងស្មារតីយុវជន និងស្មារតីគណបក្សកាន់បង្ហាញឱ្យឃើញច្បាស់នូវភាពស្អិតរមួត ដូចពាក្យស្លោកតែមួយ “**យុវជនដើម្បីគណបក្ស និង គណបក្ស ដើម្បីយុវជន**”។

# ឧបសម្ព័ន្ធ

DRAFT

# ឧបសម្ព័ន្ធ ក. ផែនការសកម្មភាពប្រចាំឆ្នាំ ២០១៩

DRAFT

## ផែនការសកម្មភាពឆ្នាំ២០១៩ របស់ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

| គោលបំណង | សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ ២០១៩ | | | | | | | | | | | | ទឹកប្រាក់ (រៀល) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | |
| សរុបទឹកប្រាក់ | | | | | | | | | | | | | | | |
| ១.បណ្តុះបណ្តាលស្មារតីសាមគ្គីភាព និងកម្លាំងគាំទ្រមាគ៌ានយោ-បាយរបស់គណបក្ស | ១.១. រៀបចំបាឋកថាស្តីពីកម្មវិធីនយោបាយគណបក្សប្រជាជន និងការលើកកម្ពស់ការយល់ដឹងពីវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសម្រាប់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានពន្ធដារ | សមាជិក យុវជនបក្សប្រចាំកសហវ ចំនួន ១០០០ នាក់ចូលរួមបាឋកថា | | | | | | | | | | | | | |
| | ១.២. រៀបចំបាឋកថាស្តីពីកម្មវិធីនយោបាយគណបក្សប្រជាជន និងការលើកកម្ពស់ការយល់ដឹងពីវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជូនដល់ គណៈកម្មាធិការសាខាបក្សផ្សេងទៀតប្រចាំ កសហវ | សមាជិកយុវ-ជនបក្សប្រចាំកសហវ ចំនួន ១០០០ នាក់ចូលរួមបាឋកថា | | | | | | | | | | | | | |
| ២. ផ្សព្វផ្សាយ និងអប់កម្មវិធីនយោបក្ស កម្មវិធី កែទម្រង់ និង សមិទ្ធផលរបស់គណបក្សទាំងកម្រិតគោលនយោ-បាយជាតិ ទាំងកម្រិត វិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២.១. រៀបចំ គេហទំព័រសម្រាប់ ក.យ.ក. | គេហទំព័រត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ | X | X | | | | | | | | | | | |
| | ២.២. រៀបចំ APPLICATION របស់ ក.យ.ក. ដើម្បីដំឡើងលើទូរស័ព្ទឆ្លាតវៃ | APPLICATION របស់ ក.យ.ក ត្រូវបានរៀបចំ | X | X | | | | | | | | | | | |
| | ២.៣.រៀបចំខ្សែវីឌីអូខ្លីស្តីពីសមិទ្ធផលសម្រេចបាន នៃ ក.យ.ក. | វីឌីអូខ្លីស្តីពីសមិទ្ធផលសម្រេចបាន នៃ ក.យ.ក. ត្រូវបានរៀបចំរួចរាល់ | X | X | | | | | | | | | | | |

DRAFT

| គោលបំណង | សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ ២០១៩ | | | | | | | | | | | | ទឹកប្រាក់ (រៀល) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | |
| | ២.៤.រៀបចំឯកសារទស្សនាទានស្តីពីការអភិវឌ្ឍន៍សហគមន៍ | | X | X | X | | | | | | | | | | |
| | ២.៥. រៀបចំកម្មវិធីចុះជួយសហគមន៍ក្រីក្រតាមបណ្តារាជធានី-ខេត្ត ជាពិសេសសាលារៀនដាច់ស្រយាល | យ៉ាងតិច១លើក/ឆ្នាំ ក.យ.ក. ចុះជួយសហ-គមន៍ក្រីក្រ | | | | | X | | | | | | | | |
| | ២.៥.រៀបចំកម្មវិធីបង្កើនភាពធ្វើការងារជាក្រុម តាមរយៈ ការហាត់កីឡា ឬ ដំណើរកំសាន្តផ្សេងៗ | យ៉ាងតិច១លើក/ឆ្នាំ មានដំណើរកំសាន្ត ឬធ្វើការសកម្ម-ភាព រួមគ្នាដើម្បីបង្កើនការធ្វើការងារជាក្រុម | | | | | | X | | | | | X | | |
| | ២.៦.រៀបចំខិតប័ណ្ណសម្រាប់ផ្សព្វផ្សាយសមិទ្ធផលរយៈពេល ៥ឆ្នាំ បាន ក.យ.ក. | ខិតប័ណ្ណត្រូវបាន បោះពុម្ពនិងផ្សព្វ-ផ្សាយ | X | X | | | | | | | | | | | |
| | ២.៧.រៀបចំផែនការយុទ្ធសាស្ត្រនៃការអភិវឌ្ឍយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំ កសហវ ឆ្នាំ២០១៩-២០២៣ | រៀបចំផែនការយុទ្ធ-សាស្ត្រនៃការអភិវឌ្ឍ យុវជន គណបក្សប្រជាជនកម្ពុជាប្រចាំ កសហវ ឆ្នាំ ២០១៩-២០២៣ | X | X | X | X | | | | | | | | | |
| | ២.៧.រៀបចំសៀវភៅផែនការប្រតិបត្តិឆ្នាំ ២០១៩ នៃ ក.យ.ក. | សៀវភៅផែនការប្រតិបត្តិត្រូវបានរៀបចំរួចរាល់ និងបោះពុម្ពផ្សព្វផ្សាយ | X | X | | | | | | | | | | | |

DRAFT

| គោលបំណង | សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ ២០១៩ | | | | | | | | | | | | ទឹកប្រាក់ (រៀល) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | |
| | ២.៨.រៀបចំរបាយ-ការណ៍សមិទ្ធកម្មប្រចាំពាក់កណ្ដាលឆ្នាំ និងប្រចាំឆ្នាំ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុពាក់កណ្ដាលឆ្នាំ និងប្រចាំឆ្នាំ | របាយការណ៍សមិទ្ធកម្ម និងហិរញ្ញវត្ថុត្រូវបានរៀបចំបានទាន់ពេលវេលា | | | | | | | X | | | | | X | |
| ៣. គាំទ្រ និងសម្រប សម្រួល កិច្ចដំណើការរបស់ ក.យ.ក. នៅក្នុងផ្ទៃក្នុងក្រសួង ព្រមទាំង ជាមួយស្ថាប័នពាក់ព័ន្ធផ្សេងទៀត ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព | ៣.១.រៀបចំប័ណ្ណ សសើរ និងថ្លែងអំណរគុណជូនសមាជិកយុវជនគណបក្សប្រចាំកសហវ | យុវជនមានស្នាដៃបានទទួលប័ណ្ណសរសើរ ឬលិខិតថ្លែងអំណរគុណ | | | | | | | | | | | | | |
| | ៣.២.ជំរុញការរៀបចំ និងការទទួលបានកាតសមាជិកបក្សរបស់យុវជនគណបក្សប្រជាជនកម្ពុជាកសហវ | សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំកសហវ ៩០% មានកាតសមាជិកបក្ស | | | | | | | | | | | | | |
| | ៣.៣. សម្របសម្រួលជាមួយគណៈកម្មាធិ-ការសាខាបក្សប្រចាំអគ្គនាយកដ្ឋានពន្ធដារលើការរៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយ និងលក្ខន្តិកៈគណបក្សប្រជាជន កម្ពុជា និង/ឬគោលនយោបាយសំខាន់ៗផ្សេងទៀតរបស់បក្ស | សមាជិកចំនួន ៥០០ នាក់ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ | | | | | | | | | | | | | |
| | ៣.៤. សម្របសម្រួលជាមួយគណៈកម្មាធិការសាខាបក្សអគ្គនាយកដ្ឋានរតនាគារជាតិលើការរៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយ និង | សមាជិកចំនួន ៨៧ នាក់ ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ | | | | | X | | | | | | | | |

DRAFT

| គោលបំណង | សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ ២០១៩ | | | | | | | | | | | | ទឹកប្រាក់ (រៀល) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | |
| | លក្ខន្តិកៈគណបក្សប្រជាជនកម្ពុជា និង/ឬ គោលនយោបាយសំខាន់ៗ ផ្សេងទៀតរបស់បក្ស | | | | | | | | | | | | | | |
| | ៣.៥. សម្របសម្រួលជាមួយគណៈកម្មាធិការសាខាបក្សនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាលើការរៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយនិងលក្ខន្តិកៈគណបក្សប្រជាជនកម្ពុជា និង/ឬគោលនយោបាយសំខាន់ៗផ្សេងទៀតរបស់បក្ស | សមាជិកចំនួន ២០០ នាក់ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ | | | | | | | | | | | | | |
| | ៣.៦. រៀបចំឯកសារទស្សនាទានស្ដីពីកម្មវិធីប្រឡងជ្រើសរើសយុវជនឆ្នើមក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ឯកសារទស្សនាទានស្ដីពីកម្មវិធីប្រឡងជ្រើសរើសយុវជនឆ្នើមក្នុងវិស័យសេដ្ឋ កិច្ចនិងហិរញ្ញវត្ថុ ត្រូវបានរៀបចំ | X | X | X | | | | | | | | | | |
| | ៣.៧. រៀបចំនូវការប្រឡងជ្រើសរើសយុវជនឆ្នើមក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កម្មវិធីប្រលងប្រជែងត្រូវបានរៀបចំ | | | | | | | | | | | | | |

DRAFT

| គោលបំណង | សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ ២០១៩ | | | | | | | | | | | | ទឹកប្រាក់ (រៀល) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | |
| | ៣.៨. រៀបចំវគ្គបណ្តុះបណ្តាលយុវជនឆ្នើមឱ្យក្លាយជាវាគ្មិនបង្គោល ដែល នឹងបំពេញមុខងារ គន្លឹះក្នុងការផ្សព្វផ្សាយបន្តអំពីគោលនយោបាយមាគ៌ានយោបាយ និងទស្សនវិស័យនយោ-បាយរបស់គណបក្សជូនដល់យុវជនគណបក្សប្រជាជនកម្ពុជា | មន្ត្រីឆ្នើមចំនួន ៥០ នាក់ចូលរួមវគ្គបណ្តុះបណ្តាល | | | | X | | | | | | | | | |

DRAFT

# ឧបសម្ព័ន្ធ ខ. ផែនការសកម្មភាពរយៈពេលមធ្យមឆ្នាំ២០១៩-២០២៣

DRAFT

# ផែនការសកម្មភាពរយៈពេលមធ្យមឆ្នាំ២០១៩-២០២៣
# របស់ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

| គោលបំណង | សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ ២០១៩-២០២៣ | | | | | ទឹកប្រាក់ (រៀល) |
|---|---|---|---|---|---|---|---|---|
| | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| សរុបទឹកប្រាក់ | | | | | | | | |
| ១. បណ្តុះបណ្តាលស្មារតីសាមគ្គីភាព និងកម្លាំងគាំទ្រមាគ៌ានយោ-បាយរបស់គណបក្ស | ១.១. រៀបចំបាឋកថាស្តីពីកម្មវិធីនយោបាយគណបក្សប្រជាជន និងការលើកកម្ពស់ការយល់ដឹងពីវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ | សមាជិកយុវជនបក្សប្រចាំកសហវ ចំនួន ១០០០ នាក់ចូលរួមបាឋកថា | | | | | | |
| | ១.២. រៀបចំបាឋកថាស្តីពីកម្មវិធីនយោបាយគណបក្សប្រជាជន និងការលើកកម្ពស់ការយល់ដឹងពីវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុជូនដល់គណៈកម្មាធិការសាខាបក្សផ្សេងទៀតប្រចាំ កសហវ | សមាជិកយុវជនបក្សប្រចាំកសហវ ចំនួន ១០០០ នាក់ចូលរួមបាឋកថា | | | | | | |
| ២. ផ្សព្វផ្សាយ និងអប់កម្មវិធីនយោបក្សកម្មវិធី កែទម្រង់ និងសមិទ្ធផលរបស់គណបក្សទាំងកម្រិតគោលនយោ-បាយជាតិ ទាំងកម្រិត វិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២.១. រៀបចំ គេហទំព័រសម្រាប់ ក.យ.ក. | គេហទំព័រត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ | X | | | | | |
| | ២.២. រៀបចំ APPLICATION របស់ ក.យ.ក. ដើម្បីដំឡើងលើទូរស័ព្ទឆ្លាតវៃ | APPLICATION របស់ ក.យ.ក ត្រូវបាន រៀបចំ | X | | | | | |
| | ២.៣. រៀបចំខ្សែវីឌីអូខ្លីស្តីពីសមិទ្ធផលសម្រេចបាន នៃ ក.យ.ក. | វីឌីអូខ្លីស្តីពីសមិទ្ធផលសម្រេចបាននៃ ក.យ.ក. ត្រូវបានរៀបចំរួចរាល់ | X | | | | | |
| | ២.៤. រៀបចំឯកសារទស្សនាទានស្តីពីការអភិវឌ្ឍន៍សហគមន៍ | ឯកសារទស្សនាទានស្តីពីការអភិវឌ្ឍន៍សហគមន៍ | X | | | | | |
| | ២.៥. រៀបចំកម្មវិធីចុះជួយសហគមន៍ក្រីក្រតាមបណ្តារាជធានី-ខេត្ត ជាពិសេស សាលារៀនដាច់ស្រយាល | យ៉ាងតិច១ លើក/ឆ្នាំ ក.យ.ក. ចុះជួយសហគមន៍ក្រីក្រ | X | X | X | X | X | |
| | ២.៥. រៀបចំកម្មវិធី បង្កើនភាពធ្វើការងារជាក្រុម តាមរយៈការហាត់កីឡា ឬ ដំណើរកំសាន្តផ្សេងៗ | យ៉ាងតិច១ លើក/ឆ្នាំ មានដំណើរកំសាន្ត ឬធ្វើការសកម្មភាព រួមគ្នា ដើម្បីបង្កើនការធ្វើការងារជាក្រុម | X | X | X | X | X | |
| | ២.៦. រៀបចំខិតប័ណ្ណសម្រាប់ផ្សព្វផ្សាយសមិទ្ធផលរយៈពេល ៥ឆ្នាំ បាន ក.យ.ក . | ខិតប័ណ្ណត្រូវបានបោះពុម្ព និងផ្សព្វផ្សាយ | X | | | | X | |

DRAFT

| គោលបំណង | សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ ២០១៩-២០២៣ | | | | | ទឹកប្រាក់ (រៀល) |
|---|---|---|---|---|---|---|---|---|
| | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | ២.៧.រៀបចំផែនការយុទ្ធសាស្ត្រនៃការអភិវឌ្ឍយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំ កសហវ ឆ្នាំ២០១៩-២០២៣ | រៀបចំផែនការយុទ្ធសាស្ត្រនៃការអភិវឌ្ឍយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំ កសហវ ឆ្នាំ២០១៩-២០២៣ | X | | | | | |
| | ២.៧.រៀបចំសៀវភៅផែនការប្រតិបត្តិប្រចាំឆ្នាំនៃ ក.យ.ក. | សៀវភៅផែនការប្រតិបត្តិត្រូវបានរៀបចំរួចរាល់ និងបោះពុម្ពផ្សព្វផ្សាយ | X | X | X | X | X | |
| | ២.៨.រៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំពាក់កណ្តាលឆ្នាំ និងប្រចាំឆ្នាំ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុពាក់កណ្តាលឆ្នាំ និងប្រចាំឆ្នាំ | របាយការណ៍សមិទ្ធកម្ម និងហិរញ្ញវត្ថុ ត្រូវបានរៀបចំបានទាន់ពេលវេលា | X | X | X | X | X | |
| | ២.៩.រៀបចំរបាយការណ៍សមិទ្ធកម្មរយៈពេល ៣ ឆ្នាំ និង ៥ ឆ្នាំ នៃការអនុវត្តផែនការយុទ្ធសាស្ត្រ | របាយការណ៍សមិទ្ធកម្ម ត្រូវបានរៀបចំ | | | X | X | | |
| ៣. គាំទ្រ និងសម្រប សម្រួលកិច្ចដំណើការរបស់ ក.យ.ក. នៅក្នុងផ្ទៃក្នុងក្រសួង ព្រមទាំង ជាមួយស្ថាប័នពាក់ព័ន្ធផ្សេងទៀត ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព | ៣.១.រៀបចំប័ណ្ណសសើរ និងថ្លែងអំណរគុណជូនសមាជិកយុវជនគណបក្សប្រចាំ កសហវ | យុវជនមានស្នាដៃបានទទួលប័ណ្ណសរសើរ ឬលិខិតថ្លែងអំណរគុណ | X | X | X | X | X | |
| | ៣.២.ជំរុញការរៀបចំ និងការទទួលបានកាតសមាជិកបក្សរបស់យុវជនគណបក្សប្រជាជនកម្ពុជា កសហវ | សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំ កសហវ ១០០% មានកាតសមាជិកបក្ស | X | X | X | X | X | |
| | ៣.៣. សម្របសម្រួលជាមួយគណៈកម្មាធិការសាខាបក្សប្រចាំ អគ្គនាយកដ្ឋានពន្ធដារលើការរៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយ និងលក្ខន្តិកៈគណបក្សប្រជាជន កម្ពុជា និង/ឬគោលនយោបាយសំខាន់ៗផ្សេងទៀតរបស់បក្ស | សមាជិកចំនួន ៥០០នាក់ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ | | | | | | |
| | ៣.៤. សម្របសម្រួលជាមួយគណៈកម្មាធិការសាខាបក្សអគ្គនាយកដ្ឋានរតនាគារជាតិលើការរៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយ និងលក្ខន្តិកៈគណបក្ស ប្រជាជនកម្ពុជា និង/ឬគោលនយោបាយសំខាន់ៗ ផ្សេងទៀតរបស់បក្ស | សមាជិកចំនួន ៨៧នាក់ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ | | | | | | |

DRAFT

| គោលបំណង | សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ ២០១៩-២០២៣ | | | | | ទឹកប្រាក់ (រៀល) |
|---|---|---|---|---|---|---|---|---|
| | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | ៣.៥. សម្របសម្រួលជាមួយគណៈកម្មាធិការសាខាបក្សនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាលើការរៀបចំសិក្ខាសាលាផ្សព្វផ្សាយគោល នយោបាយនិងលក្ខន្តិកៈគណបក្សប្រជាជនកម្ពុជា និង/ឬគោលនយោបាយសំខាន់ៗផ្សេងទៀតរបស់បក្ស | សមាជិកចំនួន ២០០នាក់ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ | | | | | | |
| | ៣.៦. រៀបចំឯកសារទស្សនាទានស្តីពីកម្មវិធីប្រឡងជ្រើសរើសយុវជនឆ្នើមក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ឯកសារទស្សនាទានស្តីពីកម្មវិធីប្រឡងជ្រើសរើសយុវជនឆ្នើម ក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានរៀបចំ | X | | | | | |
| | ៣.៧. រៀបចំទូវការប្រឡងជ្រើសរើសយុវជនឆ្នើមក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កម្មវិធីប្រលងប្រជែងត្រូវបានរៀបចំ | X | X | X | X | X | |
| | ៣.៨. រៀបចំវគ្គបណ្តុះបណ្តាលយុវជនឆ្នើមឱ្យក្លាយជាវាគ្មិនបង្គោល ដែល នឹងបំពេញមុខងារ គន្លឹះក្នុងការផ្សព្វផ្សាយបន្តអំពីគោលនយោបាយមាគ៌ានយោបាយ និងទស្សនវិស័យនយោ-បាយរបស់គណបក្សជូនដល់យុវជនគណបក្សប្រជាជនកម្ពុជា | មន្រ្តីឆ្នើមចំនួន ៥០នាក់ចូលរួមវគ្គបណ្តុះបណ្តាល | X | X | X | X | X | |

DRAFT

# ឧបសម្ព័ន្ធ គ. សមិទ្ធផលសម្រេចបានឆ្នាំ២០១៣-២០១៨

DRAFT

DRAFT

DRAFT

DRAFT

DRAFT

# ឧបសម្ព័ន្ធ ឃ. ទម្រង់រៀបចំផែនការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ និង រយៈពេលមធ្យម

DRAFT

DRAFT

DRAFT

DRAFT

DRAFT

# ឧបសម្ព័ន្ធ ខ. ទម្រង់របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងប្រចាំឆ្នាំ



DRAFT

DRAFT

DRAFT

DRAFT

# ឧបសម្ព័ន្ធ ច. ទម្រង់របាយការណ៍សមិទ្ធកម្មពាក់កណ្តាលឆ្នាំ និងប្រចាំឆ្នាំ

DRAFT

DRAFT

DRAFT

# ឧបសម្ព័ន្ធ ឆ. សេចក្តីកំណត់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

DRAFT

DRAFT

DRAFT

DRAFT

DRAFT

# ឧបសម្ព័ន្ធ ជ. សេចក្តីកំណត់ស្តីពីការកែសម្រួលប្រការ ៦ នៃសេចក្តីកំណត់ លេខ ៣៦/១៤ គប.កសហវ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

DRAFT

DRAFT

DRAFT

# ឧបសម្ព័ន្ធ ឈ. សេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

DRAFT

DRAFT

DRAFT

# ឧបសម្ព័ន្ធ ញ. សេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពបន្ថែមក្នុងក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

DRAFT

DRAFT

DRAFT

# ឧបសម្ព័ន្ធ ដ. សេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពលេខាធិការដ្ឋាននៃក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

DRAFT

DRAFT

DRAFT

# ឧបសម្ព័ន្ធ ៥. សេចក្តីសម្រេចស្តីពីការទទួលស្គាល់សមាសភាពយុវជនគណបក្ស ប្រជាជនកម្ពុជាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

DRAFT

DRAFT